**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

នាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍
និងព័ត៌មាន

# សេចក្តីជូនព័ត៌មាន

នៅថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០១៧ វេលាម៉ោង ១៦:០០ នាទីរសៀល នៅទីស្តីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នឹងអញ្ជើញធ្វើជាអធិបតីក្នុងពិធីចុះហត្ថលេខា ដូចខាងក្រោមៈ

- ឯកឧត្តម ប្រាក់ សុខុន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងឯកឧត្តម ហូរីណូអ៊ុជិ ហ៊ីដេហ៊ីសា (HORINOUCHI Hidehisa) ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពនៃប្រទេសជប៉ុនប្រចាំកម្ពុជា នឹងចុះហត្ថលេខាលើលិខិតប្តូរសារ និងកំណត់ហេតុនៃការពិភាក្សាស្តីពីការផ្តល់ហិរញ្ញប្បទានឥតសំណង និងឥណទានសម្បទានសម្រាប់គម្រោង ចំនួន០៤ ដូចខាងក្រោម៖

  ១- ហិរញ្ញប្បទានឥតសំណង ដែលមានទឹកប្រាក់សរុបចំនួន ១០៩ លានយ៉េន(ប្រមាណ ៩៨៩.៩៧៣ ដុល្លារអាមេរិក) សម្រាប់អនុវត្តគំរោង «ធ្វើឱ្យប្រសើរឡើងនូវការការពារទឹកជំនន់ក្នុងរាជធានីភ្នំពេញ តំណាក់កាលទី៤»;

  ២- ហិរញ្ញប្បទានឥតសំណង ដែលមានទឹកប្រាក់សរុបចំនួន ១.៩៥៣ លានយ៉េន (ប្រមាណ ១៧,៦៦ លានដុល្លារអាមេរិក)សម្រាប់អនុវត្តគំរោង «ធ្វើឱ្យប្រសើរឡើងមន្ទីរពេទ្យបង្អែកខេត្តបាត់ដំបង»;

  ៣- ឥណទានសម្បទាន ដែលមានទឹកប្រាក់សរុបចំនួន ១១.១៣៦ លានយ៉េន (ប្រមាណ ៩៨ លានដុល្លារអាមេរិក) សម្រាប់អនុវត្តគំរោង «ការធ្វើឱ្យប្រសើរឡើងនូវកំណាត់ផ្លូវជាតិលេខ៥ ភាគខាងជើង (ក្រុងបាត់ដំបង-ក្រុងសិរីសោភ័ណ) ជំហានទី២» ; និង

  ៤- ហិរញ្ញប្បទានឥតសំណង ដែលមានទឹកប្រាក់សរុបចំនួន ៣.២៧១ លានយ៉េន (ប្រមាណ ២៨,៥ លានដុល្លារអាមេរិក) សម្រាប់អនុវត្តគំរោង «ពង្រីកប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតក្នុងខេត្តកំពង់ធំ» ។

- ឯកឧត្តម អូន ព័ន្ធមុនីរ័ត្ន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងឯកឧត្តម យូអ៊ីជី ស៊ូហ្គាណូ (Yuichi SUGANO) ប្រធានទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh

នៃប្រទេសជប៉ុន (JICA) នៅភ្នំពេញ នឹងចុះហត្ថលេខាលើកិច្ចព្រមព្រៀងហិរញ្ញប្បទានសហប្រតិបត្តិការ ចំនួន០៣ ដូចខាងក្រោមៈ

ក-<u>កិច្ចព្រមព្រៀងហិរញ្ញប្បទានឥតសំណងៈ</u> ចំនួន០២ គំរោង ដែលមានទឹកប្រាក់ចំនួន ១.៥៦២លានយ៉េន គឺៈ

១)«ការធ្វើឲ្យប្រសើរឡើងនៃមន្ទីរពេទ្យបង្អែកខេត្តបាត់ដំបង» និង

២)«ការធ្វើឲ្យប្រសើរឡើងនូវការការពារទឹកជំនន់ ក្នុងទីក្រុងភ្នំពេញ ជំហានទី៤»។

ខ-<u>កិច្ចព្រមព្រៀងឥណទានសម្បទានៈ</u> ចំនួន០១គំរោង ដែលមានទឹកប្រាក់ចំនួន ១១.១៣៦ លានយ៉េន សម្រាប់«ការធ្វើឲ្យប្រសើរឡើងនូវកំណាត់ផ្លូវជាតិលេខ៥ ភាគខាងជើង (ក្រុងបាត់ដំបង-ក្រុងសិរីសោភ័ណ) ជំហានទី២។

ប្រទេសជប៉ុនគឺជាដៃគូដ៏សំខាន់បំផុតមួយរបស់កម្ពុជា ហើយបានរួមចំណែកជាច្រើនក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងហេដ្ឋារចនាសម្ព័ន្ធនៅកម្ពុជា។ គំរោងទាំងនេះត្រូវបានរំពឹងទុកថានឹងជួយកែលំអរដល់ការតភ្ជាប់តំបន់របស់កម្ពុជា ហើយធ្វើឲ្យប្រសើរឡើងដល់ជីវភាព និងការថែរក្សាសុខភាពរបស់ប្រជាជន ការផ្គត់ផ្គង់ទឹកស្អាត និងការការពារទឹកជំនន់។

ភ្នំពេញ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧